

# តើមានសេវាអ្វីខ្លះសម្រាប់ទារក និងក្មេងតូច HRC?

HARBOR REGIONAL CENTER

ជាញឹកញាប់ អតិថិជនរបស់យើង ឬឪពុកម្តាយ/សមាជិកគ្រួសារបានស្នើសុំព័ត៌មានអំពីសេវាដែលមាន។ យើងបានរៀបចំបញ្ជីនេះដើម្បីផ្តល់ជូនអ្នកនូវទិដ្ឋភាពទូទៅអំពីសេវាទាំងនេះ។ សូមចងចាំថា សេវាត្រូវបានកំណត់ទៅតាមបុគ្គលម្នាក់ៗ។ សេវាត្រូវតែកំណត់ទៅតាមការចាំបាច់នៅលើផែនការគ្រួសារ/បុគ្គល (IFSP) និងត្រូវផ្តល់ជូនស្របទៅតាមគោលនយោបាយសេវារបស់ មជ្ឈមណ្ឌលតំបន់ Harbor ដែលបានដាក់នៅលើវេបសាយត៍របស់យើង។

សេវាមួយចំនួនត្រូវបានផ្តល់ជូនដោយទីភ្នាក់ងារសហគមន៍ឧបត្ថម្ភដោយមូលនិធិសាធារណ ដូចជា Medi-Cal, Head Start។ល។ និងមួយចំនួនទៀតទទួលបានមូលនិធិពី HRC បន្ទាប់ពីយើងបានបំពេញតាមលក្ខខណ្ឌស្វែងរកធនធានមូលនិធិដែលអាចមានផ្សេងៗទៀតទាំងអស់។

យើងដឹងថា អ្នកចង់ដឹងអំពីប្រភេទសេវាផ្សេងៗដែលមានដើម្បីឲ្យអ្នកអាចក្លាយជាអ្នកចូលរួមដែលទទួលបានព័ត៌មានគ្រប់គ្រាន់នៅក្នុងដំណើរការរៀបចំផែនការសេវា។ ខាងក្រោមគឺជាបញ្ជីសេវា និងការគាំទ្រមួយចំនួនដែលជាទូទៅត្រូវបានណែនាំសម្រាប់ទារក និងក្មេងតូច (ចាប់ពីពេលកើតដល់អាយុបីឆ្នាំ) ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេផងដែរ។”



## សេវាដែលផ្តល់ដោយបុគ្គលិក HRC

### ការវាយតម្លៃ និងការពិគ្រោះយោបល់

អ្នកសម្របសម្រួលសេវារបស់អ្នកអាចរៀបចំការជួបប្រជុំជាមួយអ្នកជំនាញរបស់ HRC ឬក្រុមពហុវិស័យដើម្បីវាយតម្លៃតម្រូវការកូនរបស់អ្នក ក៏ដូចជាផ្តល់ជូនអ្នកនូវសេវាពិគ្រោះយោបល់ផងដែរ។ ការវាយតម្លៃ និងការពិគ្រោះយោបល់អាចជួយនៅក្នុងការផ្តល់ និងបញ្ជាក់ការធ្វើរោគវិនិច្ឆ័យ កំណត់ប្រភេទសេវា និងការគាំទ្រដែលត្រូវការ កំណត់តម្រូវការសុខភាព និងតម្រូវការសុខភាពផ្លូវចិត្តរបស់ទារក/គ្រួសារ គាំទ្រសិទ្ធិទទួលបានអត្ថប្រយោជន៍ដែលឧបត្ថម្ភដោយមូលនិធិសាធារណៈ។ល។

HRC មានអ្នកជំនាញដែលមានឯកទេសផ្នែកអភិវឌ្ឍន៍កុមារតូច ការព្យាបាលលើការនិយាយ ការព្យាបាលដោយចលនា ចិត្តវិទ្យាសុខភាពផ្លូវចិត្តសម្រាប់ទារក/គ្រួសារ អន្តរាគមន៍ចំពោះឥរិយាបថ វេជ្ជសាស្ត្រ សេនេទិច ការថែទាំអនាម័យមាត់ធ្មេញ ឱសថសាស្ត្រ អាហារូបត្ថម្ភ បច្ចេកវិទ្យាជំនួយ អត្ថប្រយោជន៍ហិរញ្ញវត្ថុ និងសុខភាព ការអប់រំពិសេស និងច្បាប់។

### ថ្នាក់អភិវឌ្ឍន៍កុមារតូច៖ រួមគ្នាតាំងពីដំបូង

ថ្នាក់សិក្សាដែលដឹកនាំដោយអ្នកឯកទេសផ្នែកអភិវឌ្ឍន៍កុមារតូចផ្តល់នូវឱកាសសម្រាប់ឪពុកម្តាយ/សមាជិកគ្រួសារ ព្រមទាំងទារក និងក្មេងតូចរបស់ពួកគាត់នៅក្នុងការប្រាស្រ័យទាក់ទងគ្នាជាមួយកុមារ និងឪពុកម្តាយផ្សេងទៀតដោយរីករាយជាមួយនឹងចម្រៀង តន្ត្រី ការធ្វើចលនា ក៏ដូចជាការសម្តែងផ្សេងៗផងដែរ។ ថ្នាក់សិក្សានេះជួយឪពុកម្តាយរៀនអំពីបច្ចេកទេសនៅក្នុងក្រុមដែលបន្ទាប់មកអាចប្រើប្រាស់នៅតាមផ្ទះដើម្បីកសាងជំនាញអភិវឌ្ឍន៍ និងប្រាស្រ័យទាក់ទងរបស់កុមារតូច។ ថ្នាក់សិក្សានេះរួមបញ្ចូលម៉ាក់/ប៉ា និងខ្លួនខ្ញុំ ការអភិវឌ្ឍភាសាសម្រាប់ក្មេងតូច តួនាទីជាឪពុកម្តាយ ការបណ្តុះបណ្តាលអំពីការប្រើប្រាស់បង្គន់ និងជំនាញផ្សេងៗទៀត។

ថ្នាក់សិក្សា និងបទបង្ហាញផ្តល់ព័ត៌មានសម្រាប់គ្រួសារត្រូវបានផ្តល់ជូនរយៈពេលពេញមួយឆ្នាំដែលផ្តោតទៅលើប្រធានបទផ្សេងៗដូចជា សារទៅកាន់ទារក តួនាទីជាឪពុកម្តាយ វគ្គសកម្មភាពរវាងឪពុកម្តាយជាមួយកូន ការបង្កើតកាលវិភាគសកម្មភាព ប្រាក់ចំណូលរបបសន្តិសុខជំនួយ (SSI) និងសេវាគាំទ្រតាមផ្ទះ (IHSS) ឥណទានតម្រូវការពិសេស។ល។ HRC ក៏ផ្តល់ជូនផងដែរនូវជំនួយសេវាបកប្រែ ការថែទាំកុមារ និងការធ្វើដំណើរនៅក្នុងការធ្វើបទបង្ហាញដែលបានកំណត់ប្រសិនបើចាំបាច់ដើម្បីឲ្យអតិថិជន ឬឪពុកម្តាយចូលរួមបាន។

### ការគាំទ្រគ្រួសារ

នៅឯមជ្ឈមណ្ឌលតំបន់ HARBOR យើងជឿជាក់ថា ប្រព័ន្ធគាំទ្រល្អប្រសើរគឺជាអត្ថប្រយោជន៍ដ៏សំខាន់សម្រាប់គ្រួសារ។ បណ្តាញព័ត៌មាន និងការគាំទ្រផ្តល់ជូនគ្រួសារនូវមូលដ្ឋានដ៏ល្អប្រសើរសម្រាប់ស្វែងរកប្រព័ន្ធសេវា ធ្វើការជ្រើសរើសក្រោយទទួលបានព័ត៌មានគ្រប់គ្រាន់ និងទទួលបានគុណភាពជីវិតកាន់តែល្អប្រសើរសម្រាប់កុមារដែលមានការអភិវឌ្ឍន៍យឺត ឬពិការភាព។ ការគាំទ្រត្រូវបានផ្តល់ជូននៅក្រោមរូបភាពក្រុមគាំទ្រឪពុកម្តាយ កម្មវិធីឪពុកម្តាយបង្ហាត់ឪពុកម្តាយនិងក្លិបបងប្អូន HRC។ សម្រាប់ព័ត៌មានលម្អិតអំពីជម្រើសគាំទ្រគ្រួសារទាំងនេះ សូមចូលមើលវេបសាយត៍របស់ HRC (RESOURCES/FAMILY) ពិភាក្សាជាមួយអ្នកសម្របសម្រួលសេវារបស់អ្នក ឬអញ្ជើញទៅកាន់មជ្ឈមណ្ឌលធនធាននិងបច្ចេកវិទ្យាជំនួយរបស់ HRC នៅ TORRANCE ឬ LONG BEACH។

### មជ្ឈមណ្ឌលធនធាន និងបច្ចេកវិទ្យាជំនួយ

មជ្ឈមណ្ឌលធនធាន និងបច្ចេកវិទ្យាជំនួយរបស់ HRC ផ្តល់ជូននូវការគាំទ្រតាមរយៈការផ្តល់ព័ត៌មាន ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកវិទ្យា និងតាមរយៈការគាំទ្រពីឪពុកម្តាយផ្សេងទៀត។ សេវារួមមានបណ្ណាល័យពហុប្រព័ន្ធផ្សព្វផ្សាយទូលំទូលាយ បន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់បច្ចេកវិទ្យាជំនួយបណ្ណាល័យឲ្យខ្ចីប្រដាប់ប្រដារក្មេងលេង ព្រមទាំងក្រុមគាំទ្រគ្រួសារ និងបងប្អូន។

### ការសម្របសម្រួលសេវា

ការរៀបចំផែនការបុគ្គលជាមួយគ្រួសារអាចមានដូចជា ការបញ្ជូនទៅ ឬនិងការសម្របសម្រួលសេវាដែលផ្តល់ដោយបុគ្គលិករបស់ HRC ទីភ្នាក់ងារសហគមន៍ ឬអ្នកផ្តល់សេវាដែលឧបត្ថម្ភមូលនិធិដោយមជ្ឈមណ្ឌលតំបន់ ការគាំទ្រសម្រាប់ការទទួលបានសេវាសមស្រប និងការពិនិត្យមើលជាប្រចាំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ឬញឹកញាប់ជាងនេះប្រសិនបើចាំបាច់។

### ការឆ្លើយតបបន្ទាន់រយៈពេលម្ភៃបួនម៉ោង

HRC រក្សាប្រព័ន្ធឆ្លើយតបបន្ទាន់រយៈពេលម្ភៃបួនម៉ោង។ ប្រសិនបើអ្នកមានស្ថានភាពត្រូវការជំនួយបន្ទាន់ និងត្រូវការទាក់ទងទៅHRC ក្រៅម៉ោងធ្វើការធម្មតា គឺនៅមានអ្នកចាំទទួលសំណើរបស់អ្នក។

# សេវានានាដែល HRC ទិញពីកម្មវិធី និងពេទ្យពិនិត្យជំងឺនៅក្នុងសហគមន៍



## សេវាឥរិយាបថ

សេវាឥរិយាបថត្រូវបានរៀបចំឡើងដើម្បីជួយដល់ឪពុកម្ដាយ/អ្នកផ្ដល់សេវាថែទាំនៅក្នុងការអនុវត្តគោលការណ៍ឥរិយាបថ និងបង្រៀនជំនាញថ្មីៗដោយប្រើប្រាស់ឧទាហរណ៍លក្ខណ:បុគ្គល និងអនុវត្តជាក់ស្តែង។

## សេវាថែទាំពេលថ្ងៃ

សម្រាប់ឪពុកម្ដាយធ្វើការរបស់កុមារដែលមិនអាចទទួលធនធានថែទាំពេលថ្ងៃធម្មតាបាន នោះ HRC អាចផ្ដល់ការគាំទ្រថែទាំពេលថ្ងៃនៅមណ្ឌលថែទាំពេលថ្ងៃធម្មតា ឬនៅផ្ទះ។

## សេវាបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារ

HRC អាចផ្ដល់សេវាបកប្រែផ្ទាល់មាត់នៅក្នុងការប្រជុំជាមួយ HRC និងការបកប្រែសំណៅឯកសារ (ផែនការសេវាបុគ្គល/គ្រួសារ) ពីភាសាអង់គ្លេសទៅជាភាសាកំណើតរបស់អតិថិជន/គ្រួសារ។

## សេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងថែទាំ

ដើម្បីបំពេញតម្រូវការសេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងថែទាំសម្រាប់អតិថិជនដែលពុំមានធនធានថែទាំសុខភាពផ្សេងទៀតដូចជា ធានារ៉ាប់រងឯកជន MEDI-CAL ឬ EPSDT (ការត្រួតពិនិត្យពីដំបូង និងជាទៀងទាត់ កម្មវិធីធ្វើរោគវិនិច្ឆ័យ និងព្យាបាល) នោះនឹងអាចមានការផ្ដល់ជំនួយតាមការចាំបាច់។ ការវាយតម្លៃលើការថែទាំ ឬការថែទាំសុខភាពតាមផ្ទះ អាចផ្ដល់ជូនដើម្បីគាំទ្រគ្រួសារនៅក្នុងការបំពេញតម្រូវការថែទាំសុខភាពពិសេស។

## បរិក្ខារ និងសម្ភារវេជ្ជសាស្ត្រ

HRC អាចផ្ដល់ការវាយតម្លៃទៅលើតម្រូវការវេជ្ជសាស្ត្រ និងផ្ដល់ជំនួយនៅក្នុងការកំណត់ធនធានសហគមន៍ផ្សេងៗដូចជា MEDI-CAL ជាដើម។ ប្រសិនបើពុំមានធនធានទាំងនេះទេ យើងអាចចូលរួមចំណែកនៅក្នុងការទិញសម្ភារ និងបរិក្ខារផ្សេងៗ ដូចជាកៅអីរុញ គ្រែបច្ចេកទេសជាដើម។ល។

## ការថែទាំជំនួសបណ្ដោះអាសន្ន

ជំនួយបណ្ដោះអាសន្នពីការថែទាំ និងគ្រប់គ្រងអាចផ្ដល់ជូនដល់ឪពុកម្ដាយ ឬអ្នកផ្ដល់សេវាថែទាំបឋមផ្សេងៗទៀតសម្រាប់អតិថិជនដែលមានកង្វះខាតធំក្នុងការថែទាំខ្លួន តម្រូវការវេជ្ជសាស្ត្រជាប្រចាំ ឬបញ្ហាឥរិយាបថផ្សេងៗ។ សេវាថែទាំជំនួសបណ្ដោះអាសន្នត្រូវបានផ្ដល់ជូននៅតាមផ្ទះរបស់អតិថិជន/គ្រួសារដោយបុគ្គលិករបស់ទីភ្នាក់ងារថែទាំតាមផ្ទះ។ នៅក្នុងការថែទាំជំនួសបណ្ដោះអាសន្នកំណត់ដោយគ្រួសារ សមាជិកគ្រួសារអាចបញ្ជូនទៅមិត្តភក្តិ ឬសាច់ញាតិដែលខ្លួនទុកចិត្តដែលបម្រើការងារឲ្យទីភ្នាក់ងារថែទាំតាមផ្ទះ ដើម្បីផ្ដល់ការថែទាំជំនួសបណ្ដោះអាសន្នសម្រាប់សមាជិកគ្រួសាររបស់អ្នក។ ការថែទាំជំនួសបណ្ដោះអាសន្នក្រៅផ្ទះអាចផ្ដល់ជូននៅតាមផ្ទះដែលមានអាជ្ញាប័ណ្ណ ប្រសិនបើមាន។

## ការបណ្ដុះបណ្ដាលជំនាញសង្គមសម្រាប់កុមារ និងក្មេងជំទង់ដែលមានបញ្ហាវិសាលគមន៍មនោវិកំត

កម្មវិធី និងក្រុមអប់រំឪពុកម្ដាយដែលដឹកនាំដោយគ្រូពេទ្យព្យាបាលជួយឪពុកម្ដាយនៅក្នុងការរៀនអំពីបច្ចេកទេសដែលអ្នកអាចប្រើប្រាស់ដើម្បីធ្វើកិច្ចការជាមួយកូននៅផ្ទះ និងជំរុញដល់ការអភិវឌ្ឍន៍កូនរបស់អ្នក។



ប្រសិនបើកូនរបស់អ្នកត្រូវការការព្យាបាលលក្ខណ:បុគ្គល ឬសេវាព្យាបាលសុខភាពឥរិយាបថដើម្បីព្យាបាលមនោវិកំត ហើយការព្យាបាលទាំងនេះត្រូវបានចាត់ទុកថាមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ នោះអ្នកសម្របសម្រួលសេវារបស់អ្នកអាចណែនាំអ្នកនៅក្នុងការទទួលបានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិតរបស់អ្នក និងទទួលបានសេវាទាំងនេះតាមរយ:ផែនការធានារ៉ាប់រងសុខភាពឯកជនរបស់អ្នក ឬតាមរយ: MEDI-CAL។

មជ្ឈមណ្ឌលថ្នាក់តំបន់អាចជួយគ្រួសារផ្នែកមូលនិធិដើម្បីចំណាយទៅលើផ្នែកដែលគ្មានធានារ៉ាប់រង ធានារ៉ាប់រងរួមគ្នា ឬទូទាត់រួមគ្នាសម្រាប់វិធីព្យាបាលនិងការព្យាបាលដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ នៅពេលផែនការធានារ៉ាប់រងសុខភាពឯកជននឹងផ្ដល់ការធានាសម្រាប់សេវាទាំងនេះ ហើយគ្រួសារអាចទទួលបានដោយផ្អែកទៅលើកម្រិតប្រាក់ចំណូលទាប។

## មធ្យោបាយដឹកជញ្ជូន

ដោយផ្អែកលើតម្រូវការបុគ្គល/គ្រួសារ HRC អាចជួយភ្ជាប់គ្រួសារទៅនឹងសេវាដឹកជញ្ជូនសមស្រួបនៅក្នុងសហគមន៍ ដូចជាសេវាដឹកជញ្ជូនសាធារណ: សេវាដឹកជញ្ជូនរួមរបស់សហគមន៍ជាដើម។ HRC ក៏ផ្ដល់ជូនផងដែរនូវជំនួយផ្នែកដឹកជញ្ជូននៅពេលចាំបាច់ដើម្បីឲ្យអតិថិជន ឬឪពុកម្ដាយអាចចូលរួមនៅក្នុងបទបង្ហាញផ្ដល់ព័ត៌មានរបស់ HRC ឬសេវាដែលបានកំណត់នៅក្នុងផែនការសេវាបុគ្គល/គ្រួសារ។

HARBOR REGIONAL CENTER

HARBOR DEVELOPMENTAL DISABILITIES FOUNDATION, INC.
21231 HAWTHORNE BLVD., TORRANCE, CA 90503
(310) 540-1711 • www.harborrc.org

May 2017